# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/១១៨

## ស្ដីពី

## ការកំណត់រមណីយដ្ឋានប្រាសាទបន្ទាយទ័ព

*****

## យើង

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌ នៃប្រាសាទបន្ទាយឆ្មារ ជារមណីយដ្ឋានការពារ ស្ថិតនៅក្នុងភូមិបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ក្នុងខេត្តបន្ទាយមានជ័យ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទបន្ទាយឆ្មារត្រូវចាត់ជា៣(បី)តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - **តំបន់ទី ១ :** ជាតំបន់រមណីយដ្ឋានប្រាសាទ ហៅថា **តំបន់ស្នូល** មានផ្ទៃក្រឡា ៤០. ៣៩៤៤ ហិកតា ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A ( 296955 ; 1549073 ) , C ( 296081 ; 1548701 )
B ( 296152 ; 1549198 ) , D ( 296874 ; 1548578 )

ដែលជាខ្សែបន្ទាត់នៅក្រៅប្រឡាយប្រវត្តិសាស្ត្រ ហើយជាអ័ក្សផ្លូវព័ទ្ធជុំវិញប្រាសាទ ។

តំបន់នេះជាតំបន់មានប្រាសាទបន្ទាយឆ្មារ សំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួល

កិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - តំបន់ទី ២ : ជាតំបន់ឧទ្យានបុរាណវត្ថុ ហៅថា **តំបន់ទ្រនាប់** មានផ្ទៃក្រឡា ៦៧.៦៦២៩ ហិកតា ស្ថិតនៅក្នុងបរិវេណចន្លោះខ្សែបន្ទាត់និយាមការនៃចំណុច A , B , C , D ខាងលើ និង ខ្សែបន្ទាត់និយាមការនៃចំណុច

A ( 296955 ; 1549073 ) , $A_1$ ( 297246 ; 1549219 )
B ( 296152 ; 1549198 ) , $B_1$ ( 295993 ; 1549391 )
C ( 296081 ; 1548701 ) , $C_1$ ( 295879 ; 1548562 )
D ( 296874 ; 1548578 ) , $D_1$ ( 297145 ; 1548364 )

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លី និង ការអភិវឌ្ឍមិនសមស្រប ។

គ - តំបន់ទី ៣ : ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថា តំបន់រណប ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតនៅក្រៅ ពីបរិវេណដែលមាននិយាមការនៃចំណុច

$A_1$ ( 297246 ; 1549219 ) , $C_1$ ( 295879 ; 1548562 )
$B_1$ ( 295993 ; 1549391 ) , $D_1$ ( 297145 ; 1548364 )

ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះ ជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទបន្ទាយទ័ព មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណោតថ្នាក់នៃតំបន់ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង កំរិតនៃសារៈសំខាន់ដោយឡែកៗ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តន៍នូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និង ការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានប្រាសាទបន្ទាយទ័ព ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧.-

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទបន្ទាយឆ្មារ អាចពិនិត្យឡើងវិញ ហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផល នៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ការអភិរក្ស និង ការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និងរាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទបន្ទាយឆ្មារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ មីនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ៩៤ ចល

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ ចក.០៣.០៣.៩៤ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

